**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Oct-2012, 15:50
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង សារី អនុលោមតាមវិធាន៨៧(៤) ពាក់ព័ន្ធទៅនឹងឯកសារដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលលោកស្រី**
**ELIZABETH BECKER**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | | លោក សុន អរុណ |
| | **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក Michiel PESTMAN |
| | | លោក Victor Koppe |
| | ពេជ អង្គ | លោក អាង ឧត្តម |

| | |
|---|---|
| Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | លោក គង់ សំអុន |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |
| | Anta GUISSE |

# ចម្លើយតប

១- កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានទទួលដំណឹងអំពីសំណើរបស់មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវអត្ថបទមួយដែលសរសេរដោយលោក David Chandler នៅឆ្នាំ១៩៨៦ ដែលមានចំណងជើងថា *ការសូត្រពិធីសពសម្រាប់ឆ្នាំ១៩៧០៖ នៅពេលសង្គ្រាមរលត់ទៅរបស់លោកស្រី* Elizabeth Becker ដែលនៅក្នុងនោះលោក David Chandler បានពិនិត្យឡើងវិញ នូវសៀវភៅនោះដែលបានបោះពុម្ពនៅពេលថ្មីៗ ("សៀវភៅពិនិត្យឡើងវិញ")[1]។ គោលបំណងនៃសំណើនោះ គឺដើម្បីធ្វើឲ្យមេធាវីការពារក្តីមានលទ្ធភាពអាចសួរដេញដោលលោកស្រី Elizabeth Becker ស្តីពីការអត្ថាធិប្បាយដែលបានធ្វើឡើងដោយលោក David Chandler នៅក្នុង សៀវភៅពិនិត្យឡើងវិញនោះ។

២- សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកនូវសៀវភៅពិនិត្យឡើងវិញនេះទេ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមានបំណងលើកឡើងនូវការសង្កេតនានាដូចតទៅនេះ ទាក់ទងទៅនឹងលទ្ធភាពនៃឯកសារទាំងនេះដែលអាចជួយដល់អង្គជំនុំជម្រះសាលាដំបូងបាន នៅក្នុងការស្វែងរកការពិតនៅពេលសវនាការ។ ទីមួយ វាគឺជាសៀវភៅពិនិត្យឡើងវិញមួយនៃការបោះពុម្ពផ្សាយសៀវភៅនោះលើកទីមួយ ពុំមែនជាការបោះពុម្ពផ្សាយសៀវភៅនោះលើកទីពីរ ដែលមាននៅក្នុងសំណុំរឿងនោះទេ។ ការបោះពុម្ពផ្សាយលើកទីពីរនេះ រួមមាន ការស្រាវជ្រាវបន្ថែមទៀតដោយអ្នកនិពន្ធរូបនោះ។ ទីពីរ ទោះបីជាអង្គហេតុពិតដែលថាសៀវភៅពិនិត្យឡើងវិញមួយនេះ ត្រូវបាននិពន្ធឡើងជាង២៥ឆ្នាំកន្លងមកហើយនោះក៏ដោយ លោក David Chandler មិនត្រូវបានគេផ្តល់ឱកាសឲ្យធ្វើអត្ថាធិប្បាយស្តីពីថាតើគាត់នៅតែប្រកាន់ជំហរដើមទាំងនោះ នៅក្នុងសៀវភៅនោះជាដដែលនៅឡើយ ឬមួយយ៉ាងណានោះទេ ទាក់ទងទៅនឹងការស្រាវជ្រាវបន្ថែមទៀតដែលគាត់បានធ្វើឡើងស្តីពីរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ទីបី បើសិនជាលោក សាស្ត្រាចារ្យ Chandler នៅពេលឥឡូវនេះ នៅតែប្រកាន់ជំហរទាំងនោះជាដដែលនៅឡើយ នោះគឺគាត់មិនត្រូវបានគេផ្តល់ឱកាសឲ្យធ្វើអត្ថាធិប្បាយស្តីពីថាតើជំហរទាំងនេះអាចត្រូវអនុវត្តផងដែរ ចំពោះការបោះពុម្ពផ្សាយសៀវភៅនោះលើកទីពីរដែលរួមបញ្ចូលនូវការស្រាវជ្រាវបន្ថែមទៀត ឬមួយយ៉ាងណានោះឡើយ។

---

[1] **E232/1** សំណើរបស់ អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងឯកសារដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលលោកស្រី Elizabeth Becker, បានជូនដំណឹងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២។

៣- ឱកាសដែលបើកឲ្យសម្រាប់ដាក់បញ្ហាទាំងនេះជូនទៅលោក David Chandler នោះគឺ នៅពេលដែលគាត់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងខែកក្កដា ឆ្នាំ២០១២។ ទោះបីជាមេធាវីការពារក្តីមិនទាន់បានកាន់កាប់ក្នុងដៃនៅឡើយ នូវឯកសារនៅត្រង់ចំណុចនោះបានទាន់ពេលវេលា ក៏ពួកគេបានដឹងអំពីមតិយល់ឃើញរបស់គាត់នៅក្នុងសៀវភៅរបស់លោកស្រី Elizabeth Becker ដែលបានបោះពុម្ពផ្សាយលើកទីមួយដែរ។ ក៏ប៉ុន្តែមេធាវីការពារក្តីមិនបានតាំងជាសំណួរណាមួយសួរទៅកាន់លោក David Chandler ទាក់ទងទៅនឹងការយល់ឃើញរបស់គាត់ចំពោះសៀវភៅនេះព្រមទាំង ការសិក្សាស្រាវជ្រាវបន្ថែមទៀតរបស់លោកស្រី Elizabeth Becker ឡើយ។ ប្រសិនការណ៍នោះត្រូវបានធ្វើរួចរាល់នោះ អង្គជំនុំជំម្រះសាលាដំបូងមុខជានឹងត្រូវបានស្ថិតនៅក្នុងស្ថានភាពល្អប្រសើរជាងនេះឆ្ងាយណាស់ ដើម្បីធ្វើការសម្រេចសុពលភាព និងភាពអាចឲ្យយកមកអនុវត្តបាននៃមតិយោបល់របស់លោក David Chandler នៅក្នុងសៀវភៅពិនិត្យឡើងវិញនេះ។ ការណ៍នេះក៏អាចផ្តល់ឲ្យផងដែរនូវភាពគួរឲ្យជឿទុកចិត្តបានកាន់តែខ្លាំងជាងនេះថែមទៀតលើភ័ស្តុតាង ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការសួរសំណួរដេញដោលផ្សេងៗនាពេលអនាគត ដោយក្រុមមេធាវីការពារក្តី ទៅកាន់លោកស្រី Becker ។ លោក Michael Vickery កុងស៊ុលតង់របស់ក្រុមមេធាវីការពារក្តីបានព្រលយឲ្យដឹងដូច្នេះដោយលោកបានថ្លែងថា "ជាការគួរឲ្យចាប់អារម្មណ៍ប្រហែលជាត្រូវបញ្ជូននូវច្បាប់ចម្លងនេះមួយច្បាប់ទៅជូនលោក David Chandler ហើយសួរគាត់ថា តើលោកគិតដូចម្តេចដែរអំពីរឿងនេះ"[2] ។

៤- អាស្រ័យហេតុនេះ ទោះបីជាសហព្រះរាជអាជ្ញាមិនជំទាស់នឹងការទទួលយកឯកសារនេះក៏ដោយ ក៏មានការសន្និដ្ឋានថា តម្លៃភ័ស្តុតាងរបស់វាត្រូវបានកំហិតត្រឹមតែហេតុផលដូចបានបញ្ជាក់ពីខាងលើតែប៉ុណ្ណោះ។ វាសមហេតុផលសម្រាប់មេធាវីការពារក្តី ដើម្បីចោទសំណួរផ្សេងៗទៅកាន់ Elizabeth Becker អំពីការដកស្រង់ជាទូទៅនូវទស្សនៈផ្សេងៗរបស់ David Chandler ទៅក្នុងសៀវភៅបោះពុម្ពលើកទីមួយរបស់គាត់។ ប៉ុន្តែសន្និដ្ឋានថា មិនយុត្តិធម៌ទេដែលមេធាវីការពារក្តីអានតែសម្រង់ជាក់លាក់ពីសៀវភៅពិនិត្យឡើងវិញដែលបានសរសេរឡើងតាំងពី២៥ឆ្នាំមកហើយនោះ ក្នុងកាលៈទេសៈដែល

[2] **ឯកសារភ្ជាប់ D ,E232/1.1.4.** ទៅនឹងសំណើរបស់ អៀង សារី អនុលោមតាមវិធាន ៨៧(៤) ស្តីពីសម្ភារៈឯកសារ ដែលអាចត្រូវបានយកទៅប្រើប្រាស់នៅក្នុងអំឡុងពេលសួរដេញដោលចំពោះលោកស្រី Elizabeth Becker, ដែលបានជូនដំណឹងកាលពីថ្ងៃទី១៩ តុលា ២០១២។

អង្គជំនុំជម្រះសាលាដំបូងគ្មានព័ត៌មានដែលអាចទុកចិត្តបាន និងបច្ចុប្បន្នភាពពីអ្នកនិពន្ធនៃសៀវភៅនេះ អំពីភាពត្រឹមត្រូវនាពេលបច្ចុប្បន្ន និងភាពអាចអនុវត្តបាននៃទស្សនៈទាំងនោះ។

៥- អភិក្រមដូច្នេះ អាចនាំឲ្យអ្នកជំនាញយល់ច្រឡំ ដើម្បីជឿថាទស្សនៈផ្សេងៗដែលលើកឡើងដោយ David Chandler នៅពេលនោះ គឺត្រូវបានបញ្ជាក់ចាប់ពីពេលនេះតទៅ ហើយអាចអនុវត្តបានចំពោះសៀវភៅបោះពុម្ពលើកទីពីររបស់គាត់ដែលមាននៅក្នុងសំណុំរឿង។ ជាមួយនឹងការដាស់តឿនឲ្យមានការប្រុងប្រយ័ត្នទាំងនេះ សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើររបស់មេធាវីការពារក្តី ដែលសុំឲ្យទទួលយកឯកសារនេះស្របតាមវិធាន៨៧(៤)ឡើយ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |